ប្រការ ១ : អនុញ្ញាតអោយលោក **ហេង ឡុក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣៦៨៤៤ ប.ប ចុះថ្ងៃទី ១១-៩-៩០ អាស័យដ្ឋានបច្ចុប្បន្នភូមិផ្កាស្លា ឃុំចំការសំរោង ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការរោងជាងក្រឡឹងដែកនៅក្នុងទីតាំង ភូមិផ្កាស្លា ឃុំចំការសំរោង ស្រុក ស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៧១ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សូ គឹមម៉ូ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០១៣០៧៤ ប.ប ចុះថ្ងៃទី០៤-០២-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិរតនៈ ឃុំ រតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការរោងជាង ក្រឡឹងដែកនៅក្នុងទីតាំងភូមិរតនៈឃុំ រតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ២៧២ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **លឿង ស៊ុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្ត សញ្ញាណប័ណ្ណលេខ ២១៦៩៣៥ ប.ប ចុះថ្ងៃទី១៦-០៨-៩០ អាស័យដ្ឋាន បច្ចុប្បន្នភូមិរតនៈ ឃុំ រតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការ រោងជាងក្រឡឹងដែក នៅក្នុងទីតាំង ភូមិរតនៈ ឃុំ រតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៧៣ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **អៀង ហ៊ាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្ត សញ្ញាណប័ណ្ណលេខ ០១៩៧០០ប.ប ចុះថ្ងៃទី២៥-០៣-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ២០ឧសភា ឃុំ ស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង៨០សេះ នៅក្នុងទីតាំង ភូមិព្រែកកញ្ឆ្រៀង ឃុំ ព្រែក នរិន្ទ ស្រុក ឯកភ្នំ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **អៀង ហ៊ាង** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូច បានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៧៤ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ទេង សាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្ត សញ្ញាណប័ណ្ណលេខ ១៥៨០០៥ ប.ប ចុះថ្ងៃទី២-០៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន

ភូមិ ដង្កោ ឃុំ ល្វា ស្រុកបវេល ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៨០សេះ នៅក្នុងទីតាំង ភូមិដង្កោ ឃុំ ល្វា ស្រុកបវេល ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ទេខ សាន់** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ១ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៧៥ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន **វើរ សុខ ចំកាត់** (WORLD SOCKS Co.,LTD) តំណាងដោយលោក YEON KWON CHUN សញ្ជាតិកូរ៉េ ភេទប្រុស អាយុ៤៦ឆ្នាំ អាស័យដ្ឋាន # 32-1 JONG AM-DONG, SUNG BUK KU, SEOUL,SOUTH KOREA កាន់លិខិតឆ្លងដែនលេខ ៥៥៧៥៦២៨ ចុះថ្ងៃទី ០២-០៥-៩៤ «បង្កើតរោងចក្រស្រោមជើងនាំចេញ » ដែលមានឈ្មោះ «រោងចក្រស្រោមជើងវើរសុខ » មានទីតាំងស្ថិតនៅ ផ្លូវលេខ ២៦៧ ភូមិ១៣ សង្កាត់ ទឹក ល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រផលិតស្រោមជើងដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាននិងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវអនុញ្ញាតអោយផលិតនូវ «ស្រោមជើង» ទៅតាមគំរូនិងផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសកិច្ចសន្យា នឹងប្រការណាមួយដែលមានចែងខាងលើប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៧៦ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន វីនណឺ ហ្គាមេន (WINNER GARMENTS MANUFACTURING Co.,LTD) តំណាងដោយលោក HUANG TEH HSIANG ជនជាតិតៃវ៉ាន់ ភេទ ប្រុស អាយុ៥៨ឆ្នាំ អាសយដ្ឋាន No 121 Neythal Road Jurong SINGAPORE កាន់លិខិតឆ្លងដែនលេខ M១០៥៧ ២៩២០ ចុះថ្ងៃទី ១១-០៥-៩៥«បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ» ដែលមានឈ្មោះ « រោងចក្រកាត់ដេរ វីនណឺហ្គាមេន » មានទីតាំងស្ថិតនៅអតីតរោងចក្រសាប៊ូផ្សារដេប៉ូ ផ្ទះលេខ ១៦ ផ្លូវលេខ ២០៦ ក្រុមទី ២៤ សង្កាត់ផ្សារដេប៉ូទី ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាព បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ ផលិតផល «សំលៀកបំពាក់» ទៅតាមគំរូ ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលមានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៧៧ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ែន ហ៊ុយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤១៧៨៧ ភ.ព ចុះថ្ងៃទី ១៦-០១-៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៨៦ ផ្លូវ ៤៥៤ សង្កាត់ទួលទំពូងទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតនំប៉័ងយីហោ «ទួលទំពូង» នៅក្នុងទីតាំងដីឡូត៍លេខ ៨៤ ផ្លូវលេខ ៤៥៤ សង្កាត់ទួលទំពូង ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៧៨ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ហុង ម៉ៅ** ម្ចាស់ឧស្សាហកម្មផលិតកៅស៊ូកង យីហោ «ហុងម៉ៅ» សញ្ញា «រូបដី» បើកសាខាផលិតកម្មចំនួន ០១ កន្លែង ដែលមាន

ទីតាំងនៅផ្លូវទំនប់ថ្មី ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ប្រការដែលមានចែងក្នុងប្រកាសលេខ ២៣៣ ផក.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៧ នៅមានតំលៃជាធរមានបញ្ញត្តិដដែល ។

ប្រការ ៣ : ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស ប្រធានមន្ទីរនៃ ទីស្តីការក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល រាជធានីភ្នំពេញ និង លោក **ម៉ៅ ហុង** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗ ខ្លួន ។

ប្រការ ៤ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតរៀងទៅ ។

* * *

ប្រកាសលេខ ២៧៩ ផក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ហុក ហួត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៥៤៦១៤ ភ.ព ចុះថ្ងៃទី ០៧-០៨-៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្លូវលេខ ៦៩ អឺ០ ផ្លូវលេខ ១៥៤ សង្កាត់ ផ្សារកណ្តាលទី ២ ខ័ណ្ឌដូនពេញរាជធានីភ្នំពេញបន្តដំណើរការរោងជាងក្រឡឹងដែកនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨០ ឯក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឈូ ហុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៨២៨៩៩ ភ.ព ចុះថ្ងៃទី ២២-០៦-៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៧០ អឹ០ ផ្លូវលេខ១៤៨ សង្កាត់ផ្សារកណ្តាលទី ២ ខ័ណ្ឌដូនពេញរាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែកនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨១ ឯក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ ម្នាត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៦២៩១ ភ.ព ចុះថ្ងៃទី ៣០-៩-៩១ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៤៤ អឹ០ហ្សេត ផ្លូវព្រះសីហនុ សង្កាត់ បឹងកេងកង២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែកនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨២ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **តាំង ឌី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៦៨៤៨ ភ.ព ចុះថ្ងៃទី ២៥-០២-៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២០ អឺ០ ផ្លូវលេខ ១៥៤ សង្កាត់ ផ្សារកណ្តាលទី២ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែកនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៣ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **តាំង ម៉េងហុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៤៧៧៦៨ ភ.ព ចុះថ្ងៃទី ១៨-៧-៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៣៣ អឺ០ ផ្លូវលេខ ១៥៤ សង្កាត់ ផ្សារកណ្តាលទី ១ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែកនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៤ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **តាំង តៅ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២២០៦៦ ភ.ព ចុះថ្ងៃទី ២១-០៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៦៣ អឺ០ ផ្លូវលេខ ១៤៨ សង្កាត់ផ្សារកណ្តាលទី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែកនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៥ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ទឹក ទើ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៨០៦៧ ភ.ព ចុះថ្ងៃទី ០៤-០១-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៤៤ ដេ ផ្លូវលេខ ៣១០សង្កាត់ បឹងកេងកងទី ២ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែក និងផលិតទ្វារដែក នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៦ ឧក. ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ិន ឃុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២៧៧៥៣ ភ.ព ចុះថ្ងៃទី ០៩-៥-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៤៦ សេហ្សិត ផ្លូវលេខ៤៨០ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចកិនជ័រ និងផលិតកៅស៊ូកង់ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៧ ឧក. ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឈិន ឈាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១០៦៦០៧ ភ.ព ចុះថ្ងៃទី ២៣-៤-៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ១០៥៣ ផ្លូវជាតិលេខ២ សង្កាត់ ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការរោងជាងផលិតស៊ីទែន និងផ្សារដែកនៅក្នុងទីតាំងដីឡូត៍លេខ ១៣១ ផ្លូវលេខ២៥៤ សង្កាត់បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ២៨៨ ផក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ហ៊ុន សៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧៤៣៦៤ ភ.ព ចុះថ្ងៃទី ២២-០២-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៨៤អ៊ី០ ផ្លូវកម្ពុជាក្រោម សង្កាត់មនោរម្យ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតនំប៉័ង យីហោ «ម្កុដពេជ្រ» នៅក្នុងទីតាំងផ្ទះលេខ ៨៤ អ៊ី០ ផ្លូវកម្ពុជាក្រោម សង្កាត់មនោរម្យ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៩ ផក.ប្រក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ខែម ណារត** ជាម្ចាស់ឡផលិតឥដ្ឋក្បឿង ដែលមានទីតាំងភូមិក្តីចាស់ ឃុំចាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ផ្ទេរភារកិច្ចគ្រប់គ្រងលើសិប្បកម្មនេះជូនលោក **ទឹម ញ៉ិល** វិញ ។

ប្រការ ២ : ទទួលស្គាល់លោក **ទឹម ញ៉ិល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩៤១៤៤ ក.ណ ចុះថ្ងៃទី ០២ -៦ -៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្តីចាស់ ឃុំចាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ជាម្ចាស់សិប្បកម្មផលិតឥដ្ឋ-ក្បឿងដែលទីតាំងដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ិត ប្រាំង

* * *

ប្រកាសលេខ ២៩០ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ខៃ្វ គេខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០៦៦២៣០ ប.ប ចុះថ្ងៃទី ២៥-៨-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ អូរខ្ចាយ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្ត បាត់ដំបង បន្តដំណើរការរោងម៉ាស៊ីន កិនស្រូវកំលាំង ២៤សេះ នៅក្នុងទីតាំងភូមិអូរស្រឡៅ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ខៃ្វ គេខ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩១ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានលោក **ឡោ ខុយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧១៣៨០ប.ប ចុះថ្ងៃទី ១៥-៨-៨៧ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិកំពង់អំបិល ឃុំវត្តតាមិម ស្រុកសង្កែ ខេត្ត បាត់ដំបង បន្តដំណើរការផលិតកម្មដោយប្រើកំលាំង ១៨ សេះ នៅក្នុងទីតាំងភូមិកំពង់អំបិល ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឡោ ខុយ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩២ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានលោក **សាយ ម៉េត** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧១០៤៧ប.ប ចុះថ្ងៃទី២-៩-៨៧ ជាប្រធាន អាស័យដ្ឋាន បច្ចុប្បន្ន ភូមិអូរខ្ចាយ ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ នៅក្នុងទីតាំងភូមិអូរខ្ចាយ ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង។

ប្រការ ២ : លោក **សាយ មឿត** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩៣ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **មិន ផន** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៧៥៦៣ ប.ប ចុះថ្ងៃទី ០៣-៣-៨៨ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិរាមគន់ ឃុំតារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីន កំលាំង១២០សេះ នៅក្នុងទីតាំងភូមិឫស្សី១ ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង។

ប្រការ ២ : លោក **មិន ផន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩៤ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ផន ឈា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៤២៩២ ប.ប ចុះថ្ងៃទី ២៧-០២-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកន្សែបន្ទាយ ឃុំមោងឬស្សី ស្រុក មោងឬស្សី ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង៤០សេះ នៅក្នុងទីតាំង ភូមិ កន្សែបន្ទាយ ឃុំមោង ស្រុកមោងឬស្សី ខេត្តបាត់ដំបង។

ប្រការ ២ : លោក **ផន ឈា** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ១ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩៥ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានអ្នកស្រី **ស៊ុម ហ៊ី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៥៨៦៧ ប.ប ចុះថ្ងៃទី ២៣-៣-៨៨ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្ន ភូមិចុងសំណាយ ឃុំជ្រៃ ស្រុកមោងឬស្សី ខេត្តបាត់ ដំបង បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ៨០ សេះ នៅក្នុងទី តាំងភូមិចុងសំណាយ ឃុំជ្រៃ ស្រុកមោងឬស្សី ខេត្តបាត់ដំបង។

ប្រការ ២ : អ្នកស្រី **ស៊ុម ហ៊ី** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្គរលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

៣_ ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៩១/៩៧ ពម.ប្រក

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១-១១-១៩៩៣
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ព «យូ ឃាង» ចុះថ្ងៃទី២៦-០២-៩៧

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **យូ ឃាន** ស្ថិតនៅផ្ទះលេខ ៨២ អឺ០ ផ្លូវ ១៨៣ ក្រុមទី ៧៦ សង្កាត់វាលវង់ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « **យូ ឃាន** » ទីតាំងស្ថិតនៅ ដូចក្នុងអាស័យដ្ឋានខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របតាម ទំនៀមទំលាប់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍ នៃក្រសួងពត៌មាន និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២១២ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា « ក្បែកតាសរ »

មកជាសាលាបឋមសិក្សា «ហ៊ុន សែន ក្បែកតាសរ »

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ - ៧ -៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ សន.រកត ០៧៩៦-៥២ ចុះថ្ងៃទី២៦/៧/៩៤ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ១២ឆ្នាំ ។
- បានឃើញលិខិតលេខ ២១៨/៩៦ ខ២ន ចុះថ្ងៃទី១៨/៩/៩៦ របស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- បានឃើញលិខិតស្នើសុំរបស់ការិយាល័យអប់រំយុវជន និងកីឡាស្រុកពារាំងចុះថ្ងៃទី ១៩/១/ ៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និងកីឡាខេត្ត ព្រៃវែង ប្តូរឈ្មោះ សាលាបឋមសិក្សា «ព្រែកតាសរ » ដែលមានទីតាំងស្ថិតនៅឃុំ ព្រែកតាសរ ស្រុកពារាំង ខេត្ត ព្រៃវែង មកជាសាលាបឋមសិក្សា « ហ៊ុន សែន ព្រែកតាសរ » វិញចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរអប់រំយុវជន និងកីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិងកីឡា ខេត្តព្រៃវែង ប្រធានការិយាល័យអប់រំ ស្រុកពារាំងនាយកសាលាបឋមសិក្សា «ហ៊ិន សែន ព្រែកតាសរ» មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាមាន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២១៣ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា « ពោធិវ៉ៃ »

មកជាសាលាបឋមសិក្សា « ស៊ើ យ៉ោគពោធិវ៉ៃ »

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ - ៧ -៩៤

- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជាលេខ នស.រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦/៧/៩៤ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ ។
- បានឃើញលិខិតលេខ ៦០៤ អយក.ព.វ ចុះថ្ងៃទី៣០/១២/៩៦ របស់មន្ទីរអប់រំយុវជន និង កីឡា ខេត្តព្រៃវែង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និងកីឡាខេត្ត ព្រៃវែង ប្ដូរឈ្មោះ សាលាបឋមសិក្សា «ពោធិជ្រៃ » ដែលមានទីតាំងស្ថិតនៅឃុំ ស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង មកជាសាលាបឋមសិក្សា «សឿ យ៉ាតពោធិជ្រៃ » វិញចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរអប់រំយុវជន និងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តព្រៃវែង ប្រធានការិយាល័យអប់រំស្រុកព្រៃវែងនាយកសាលាបឋមសិក្សា «សឿ យ៉ាតពោធិជ្រៃ » មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សារុន

* * *

៥_ នីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

ភ្នំពេញ,ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៤៦ បទ

ស្តីពីថ្លៃប្រើប្រាស់សេវាទូរគមនាគមន៍ក្នុងប្រទេសនិង អន្តរជាតិ

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥_៣_១៩៨៧ របស់ក្រុមប្រឹក្សា រដ្ឋមន្ត្រីស្តីអំពីប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញសេចក្តីសំរេចលេខ ១៥៥ សសរ ចុះថ្ងៃទី ១១_១២_១៩៩១ របស់ក្រុមប្រឹក្សា រដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតំលៃ

សំរេច

ប្រការ ១ : កំណត់ថ្លៃប្រើប្រាស់សេវាទូរគមនាគមន៍ក្នុងប្រទេស និង អន្តរជាតិ មួយចំនួនដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ ដល់ឧបសម្ព័ន្ធទី ៦ ភ្ជាប់នឹងសេចក្តីប្រកាសនេះ ។

ប្រការ ២ : ប្រកាសលេខ ០៣៨ បទ ចុះថ្ងៃទី ១១ ខែ កម្ភៈ ឆ្នាំ ១៩៩៥ ព្រមទាំងឧបសម្ព័ន្ធទី ៦ ស្តីពីការផាកពិន័យលេខ ២៧៤៨ បទ ចុះថ្ងៃទី ០៥_១០_១៩៩៥ និងប្រកាសស្តីពីថ្លៃប្រើប្រាស់ សេវាទូរគមនាគមន៍ក្នុងប្រទេសនិងអន្តរជាតិលេខ

០៥៥ បទ ចុះថ្ងៃទី ០៣ ខែ ៥ ឆ្នាំ ១៩៩៦ រួមទាំងប្រកាសទាំងឡាយណាដែលមានពីមុនហើយមានន័យផ្ទុយពីប្រកាសនេះទុកជានិរាករណ៍ ។

ប្រការ ៣ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យនិងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និងនាយកដ្ឋានប្រៃសណីយ៍ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សុ យុន

ឧបសម្ព័ន្ធទី១ : ថ្លៃប្រើប្រាស់លេខអាកាសវិទ្យុ

សំគាល់ :

- រយៈពេលកំណត់នៃអាជ្ញាប័ណ្ណមានមួយឆមាស ឬ មួយឆ្នាំ ។ ក្នុងករណីអាជ្ញាប័ណ្ណមានរយៈពេលមួយឆមាសតំលៃអាជ្ញាប័ណ្ណស្មើនឹងពាក់កណ្តាលនៃតំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។
- ការសុំប្រើប្រាស់បន្តដោយគ្មានប្រការណាមួយប្រែប្រួលនៅក្នុងអាជ្ញាប័ណ្ណចាស់ គឺត្រូវបង់តែតំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំសំរាប់អាជ្ញាប័ណ្ណថ្មី ។
- អ្នកកោសលុប ឬ ក្លែងបន្លំដោយប្រការណាមួយនៅលើអាជ្ញាប័ណ្ណ ត្រូវទទួលទោសតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។
- បន្ទារហ្វេកង់នៃវិទ្យុមានពីរផ្នែកគឺផ្សាយនិងទទួល ប៉ុន្តែការគិតតំលៃហ្វ្រេកង់គិតតែមួយចំហៀងទេ ។
- អានុភាពផ្សាយគិតតាមអានុភាពអតិបរិមានៃបរិក្ខារ ។

១_ថ្លៃផ្តល់វិញ្ញាបនប័ត្រ	$
_ការីវិទ្យុ	១៥
_វិទ្យុអាម៉ាទ័រ ថ្នាក់ទី ១	១៥
_វិទ្យុអាម៉ាទ័រ ថ្នាក់ទី ២	១២
_វិទ្យុអាម៉ាទ័រ ថ្នាក់ទី ៣	១០
២_វិទ្យុប្រភេទ MF	$
ក_វិទ្យុ MF ចល័ត	
_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿង	៥
_ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើងលើនាវា	១៥
_ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើងលើដីគោក	១០
_តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ឋបនភ័ណ្ឌមួយគ្រឿងៗ :	
ចំពោះអានុភាព X watt និងបន្ទាត់ហ្វ្រេកង់Y KHz	២០+១.៣X + ២ Y
ខ_វិទ្យុប្រភេទ MF អចល័ត	
_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ :	៥
_ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើង	១០
_តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ឋបនភ័ណ្ឌមួយគ្រឿងៗ	
ចំពោះអានុភាព X watt និងបន្ទាត់ហ្វ្រេកង់Y KHz	២០+០.៧X + ២ Y
៣_វិទ្យុប្រភេទ HF	$
ក_វិទ្យុប្រភេទ HF ចល័ត	
_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ	៥
_ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើងលើនាវា	១៥
_ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើងលើដីគោក	១០
_តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំសំរាប់ឋបនភ័ណ្ឌមួយគ្រឿងៗ :	
ចំពោះអានុភាព X watt និងបន្ទាត់ហ្វ្រេកង់ Y KHz	២០+១.៥X + ២ Y

ខ_វិទ្យុប្រភេទ HF អចល័ត

–ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ថបនភ័ណ្ឌមួយគ្រឿងៗ	៥
–ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំឡើង	១០
–តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ថបនភ័ណ្ឌមួយគ្រឿងៗ	
ចំពោះអានុភាព Xwatt និងបន្ទាត់ហ្វ្រេកង់ Y KHz	២០+០.៨ X + ២ Y

៤_វិទ្យុប្រភេទ VHF | $

ក_វិទ្យុប្រភេទ VHF ចល័ត

–ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ថបនភ័ណ្ឌមួយគ្រឿងៗ	៤
–ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើង	
ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (Walkie talkie)	៥
ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា	១០
ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី	៨
–តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ថបនភ័ណ្ឌមួយគ្រឿងៗ :	
ចំពោះអានុភាព Xwatt និងបន្ទាត់ហ្វ្រេកង់ Y KHz	១០+០.៦X + ០.៤ Y

ខ_វិទ្យុប្រភេទ VHF អចល័ត

–ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ថបនភ័ណ្ឌមួយគ្រឿងៗ	៤
–ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើង	៥
–តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំសំរាប់ថបនភ័ណ្ឌមួយគ្រឿងៗ :	
ចំពោះអានុភាព Xwatt និងបន្ទាត់ហ្វ្រេកង់ Y KHz	១០+០.៤ X + ០.៤ Y

៥_វិទ្យុប្រភេទ UHF និង SHF | $

៥_១_វិទ្យុប្រភេទ UHF ចល័ត (PTT: Press to talk)

–ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ថបនភ័ណ្ឌមួយគ្រឿងៗ	៤
–ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើង :	
ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (Walkie talkie)	៥
ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា	១០

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅល្បើងី ៨

_តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ឋបនភ័ណ្ឌមួយគ្រឿងៗ :

ចំពោះអានុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ១០+0.៥ X + 0.៤ Y

៥.២_វិទ្យុប្រេគេន UHF អចល័ត (PTT)

_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ៤

_ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើង ៥

_តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ឋបនភ័ណ្ឌមួយគ្រឿងៗ :

ចំពោះអានុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ១០+0.៣ X + 0.៤ Y

៥.៣_វិទ្យុប្រេគេន UHF និង SHF ជាប្រព័ន្ធ

៥.៣.១_វិទ្យុប្រេគេនចល័ត

សំគាល់

_ តំលៃហ្វ្រេកង់គិតតាមសមាមាត្រនៃការបំពាក់ឧបករណ៍ប្រើក្នុងប្រព័ន្ធនោះ គឺប្រសិនបើប្រព័ន្ធវិទ្យុដែលដាក់នោះសំរាប់ចំណុះ ៨ × ២ MBit/s តែគេបំពាក់ឧបករណ៍សំរាប់ដំណើរការតែ ៤ × ២ MBit/s នោះតំលៃត្រូវគិតស្មើនិង ៤ ភាគ ៨ នៃតំលៃពេញ ។

_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ៥

_ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើង ២០

_តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ឋបនភ័ណ្ឌមួយគ្រឿងៗ :

ក_ហ្វ្រេកង់ទាបជាង ១ GHz

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ២០+ ១00 X + ១ Y

ខ_ហ្វ្រេកង់ ១_៣ GHz

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ២០+ ៧៥ X + 0.៨ Y

គ_ហ្វ្រេកង់ចន្លោះ ៣_៨ GHz

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ២០+ ៥0 X + 0.៦ Y

ឃ_ហ្វ្រេកង់ពី ៨ GHz ឡើងទៅ

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ២០+ ២៥ X + 0.៤ Y

៥.៣.៩_ទិន្សប្រូតេនអេចលីត

_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ៥

_ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើង ២០

_តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ឋបនភ័ណ្ឌមួយគ្រឿងៗ :

ក_ប្រេកង់ទាបជាង ១ GHz

_ចំពោះអនុភាព Xwatt និងបន្ទារប្រេកង់ Y KHz ២០+ ១០០ X + ០.៨ Y

ខ_ប្រេកង់ពី ១_៣ GHz

_ចំពោះអនុភាព Xwatt និងបន្ទារប្រេកង់ Y KHz ២០+ ៧៥ X + ០.៦ Y

គ_ប្រេកង់ចន្លោះ ៣_៨ GHz

_ចំពោះអនុភាព Xwatt និងបន្ទារប្រេកង់ Y KHz ២០+ ៥០ X + ០.៤ Y

ឃ_ប្រេកង់ ៨ GHz ឡើងទៅ

_ចំពោះអនុភាព Xwatt និងបន្ទារប្រេកង់ Y KHz ២០+ ២៥ X + ០.២ Y

៥.៤_ទិន្សប្រូតេន TLMRS, ប្រព័ន្ធទូរស័ព្ទចល័ត ឬ ទូរស័ព្ទអចល័តគតប្រើខ្សែ **សំគាល់**

_ចំពោះបរិក្ខារតូច ១ ឬ កាន់ជាប់និងដៃ ពុំចាំបាច់មានអាជ្ញាប័ណ្ណទេ ។ $

_ការទទួលពាក្យពិនិត្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ៣០

_ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗមុនពេលតំលើង ៥០

_តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ដំណើរការនៃប្រព័ន្ធទូទាំងប្រទេស :

ក_ប្រេកង់ទាបជាង ១ GHz

_ចំពោះអនុភាព Xwatt និងបន្ទារប្រេកង់ Y KHz ១០០+ ៣០ X + ២ Y

ខ_ប្រេកង់ពី ១_៣ GHz

_ចំពោះអនុភាព Xwatt និងបន្ទារប្រេកង់ Y KHz ១០០+ ៤០ X + ១.៨ Y

គ_ប្រេកង់ចន្លោះ ៣_៨ GHz

_ចំពោះអនុភាព Xwatt និងបន្ទារប្រេកង់ Y KHz ១០០+ ៤០ X + ១.៦ Y

ឃ_ ហ្វ្រេកង់ពី ៨ GHz ឡើងទៅ

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ១០០+ ៤០ X + ១.៤ Y

៦_ វិទ្យុទាក់ទងអន្តរជាតិ (ក្នុងករណីមានការអនុញ្ញាតពិសេស) $

_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ១០

_ការពិនិត្យបច្ចេកទេសមួយគ្រឿងៗមុនពេលតំលើង ២០

_តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់មួយគ្រឿងៗ ២០+ ០.៨ X + ២ Y

៧_ វិទ្យុផ្សាយសំលេង $

_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ៣០

_ការពិនិត្យបច្ចេកទេសមួយគ្រឿងៗមុនពេលតំលើង ៥០

ក_ តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ MF (MW) AM:

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ១០០+ ០.០៥ X + ២០ Y

ខ_ តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ HF (FW) AM:

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ១០០+ ០.០៥ X + ២០ Y

គ_ តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ VH FM:

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz ១០០+ ០.០៥ X + ២ Y

៨_ ទូរទស្សន៍ $

_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ៣០

_ការពិនិត្យបច្ចេកទេសមុនពេលតំលើង ៥០

ក_ តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំចំពោះទូរទស្សន៍ប្រភេទ VHF :

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់ Y KHz១០០+ ០.០៥ X+ ០.០៥ Y

ខ_ តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ UHF:

_ចំពោះអនុភាព Xwatt និងបន្ទារហ្វ្រេកង់Y KHz១០០+ ០.០៥ X+ ០.០៤ Y

៩_ វិទ្យុអាម៉ាទ័រ $

_ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ១០

_ការពិនិត្យបច្ចេកទេសមុនពេលតំលើង ៥

–តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ	២៥
១០–អ៊ិនម៉ារសាត	**$**
ក–អ៊ិនម៉ារសាតគ្រប់ប្រភេទ A,B , និង C ប្រើប្រាស់លើដីគោក	
–ការទទួលពិនិត្យពាក្យសុំប្រើប្រាស់	១០០
–តំលៃប្រើប្រាស់ស្មើនឹងតំលៃរបស់ស្ថានីយ៍អ៊ិនម៉ារសាតលើដី	+៣០ %
–ប្រាក់កក់សំរាប់ទូទាត់តំលៃនៃការប្រើប្រាស់អ៊ិនម៉ារសាតមួយគ្រឿង	១.០០០
ខ–អ៊ិនម៉ារសាតប្រភេទ A,B និង C នៅលើនាវា ,	
–ការទទួលពិនិត្យពាក្យសុំប្រើប្រាស់	១០០
–តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ	២០០

ចំពោះអ៊ិនម៉ារសាតប្រភេទ A,B និង C នៅលើនាវា អតិថិជនអាចជ្រើសរើសយកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬ អង្គការណាមួយក៏បាន ធ្វើជាអាជ្ញាធរទូទាត់ (Accounting Authority) សំរាប់ទូទាត់តំលៃជាមួយស្ថានីយ៍អ៊ិនម៉ារសាតលើដី ។

ប្រសិនបើជ្រើសរើសយកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ជាអាជ្ញាធរសំរាប់ទូទាត់តំលៃ:

–តំលៃប្រើប្រាស់ស្មើនឹងតំលៃរបស់ស្ថានីយ៍អ៊ិនម៉ារសាតលើដី	+១០ %
–ប្រាក់កក់សំរាប់ទូទាត់តំលៃនៃការប្រើប្រាស់អ៊ិនម៉ារសាតមួយគ្រឿង	៣.០០០

គ–ចំពោះអ៊ិនម៉ារសាត M

ដែលចុះឈ្មោះនៅបរទេស ហើយនាំចូល មកប្រើប្រាស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា :

–ការទទួលពិនិត្យពាក្យសុំប្រើប្រាស់	៣០
–តំលៃអាជ្ញាប័ណ្ណ :	
តិចជាង ២០ ថ្ងៃ	២៥/ថ្ងៃ
ពី២០–២៥ថ្ងៃ	៥០០
ចាប់ពី ២៥ ថ្ងៃឡើងទៅ	២០/ថ្ងៃ

ឧបសម្ព័ន្ធទី ២ : ថ្លៃប្រើប្រាស់បរិមាណទិន្នន័យអន្តរជាតិ

ថ្លៃខាងក្រោមនេះមិនរាប់បញ្ចូលថ្លៃនៃប្រព័ន្ធទិន្នន័យក្នុងប្រទេសឡើយ ។

១_បរិបទអក្សរលេខ (Digital circuits)

ល្បឿន KBit/s	ថ្លៃក្នុងមួយខែ $	ថ្លៃស្ថាបនា $
២,៤	១.៥០០	៨០០
៤,៨	២.៥០០	១.០០០
៩,៦	៣,៣០០	១.៣០០
១៩,២	៤.០០០	១.៦០០
៤៨ ឬ ៥៦ ឬ ៦៤	៦,២០០	២.០០០
១២៨	៩,៨០០	២.៤០០
១៩២	១៣.៥០០	២.៨០០
២៥៦	១៦.២០០	៣.០០០
៣៨៤	២២.២០០	៣.៥០០
៥១២	២៨.៤០០	៤.០០០
៧៦៨	៤០.០០០	៤.៥០០
១០២៤	៤៨.៧០០	៥.០០០
១៥៤៤	៥៩.០០០	៦.០០០
២០៤៨	៦៦.០០០	៦.៥០០

២_បរិបទអាណាឡូក (Analogue circuits)

ប្រទេស	ថ្លៃក្នុងមួយខែ $	ថ្លៃស្ថាបនា $
ឡាវ ថៃ និង វៀតណាម	៤.០០០	១.៦០០
ប្រទេសដទៃ	៥.០០០	១.៦០០

៣_ចំពោះការជួលខ្សែតិចជាងមួយខែត្រូវគិតតំលៃដូចតទៅ :

១_បើតិចជាងកន្លះខែ :(តំលៃប្រចាំខែ) X ៥០ % + (តំលៃប្រចាំខែ) ÷ ៣០ថ្ងៃ X (ចំនួនថ្ងៃដែលប្រើ)

២_បើលើសពីកន្លះខែ : គិតថ្លៃមួយខែ។

ឧបសម្ព័ន្ធទី ៣ : ថ្លៃបញ្ជូនរូបភាពទៅអន្តរជាតិ

ថ្លៃត្រឹមពាក់កណ្តាលផ្លូវ (គឺពីប្រទេសកម្ពុជាទៅផ្កាយរណប)

១_ការបញ្ជូនតាមប្រព័ន្ធ អ៊ិនតែលសាត (**Intelsat**)	$
១០_នាទីដំបូង	៦០០
រាល់មួយនាទីក្រោយ	៣០
១_ការបញ្ជូនតាមប្រព័ន្ធ អ៊ិនទើស្ពុតនិក (**Intersputnik**)	$
១០_នាទីដំបូង	៤៤០
រាល់មួយនាទីក្រោយ	១២

ឧបសម្ព័ន្ធទី ៤ : ថ្លៃប្រើប្រាស់ទូរស័ព្ទ

	$
ការស្ថាបនាខ្សែ	៣៨០
ការជួលជាប្រចាំខែ	៨០
<u>ថ្លៃប្រើប្រាស់ក្នុងប្រទេស</u>	$ (ក្នុងមួយនាទី)
	០,៣០
<u>ថ្លៃប្រើប្រាស់ទៅអន្តរជាតិ</u>	$ (ក្នុងមួយនាទី)
ប្រទេសលាវ ថៃ និង វៀតណាម	៣,២០
ប្រទេសអាស៊ីដទៃ	៣,៤០
ប្រទេសដទៃ	៣,៨០

ឧបសម្ព័ន្ធទី ៥ : ថ្លៃសុំច្បាប់ដាក់ប្រើបរិធានទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា (Type Approval)

	$
ទូរស័ព្ទធម្មតា	១.០០០
ទូរស័ព្ទចល័ត	៣.០០០
ផេចជិញ	១.០០០
ទូរសារ	៣.០០០
បមាណី (PABX)	៣.០០០

បរិក្ខារវិទ្យុ	២.០០០
ការសុំបង្កើតភ្នាក់ងារនាំបរិធានទូរគមនាគមន៍ចូលប្រទេសកម្ពុជា	១.០០០
ថ្លៃប្រចាំឆ្នាំ	១០០

ឧបសម្ព័ន្ធទី ៦ : ការផាកពិន័យ

សំគាល់ : ប្រាក់ពិន័យពុំមែនជាប្រាក់សំរាប់ទូទាត់តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

៦_១ ការប្រើប្រាស់បរិក្ខារវិទ្យុមួយគ្រឿងទោះចល័តក្តី អចល័តក្តី ហើយគ្មានអាជ្ញាប័ណ្ណប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារវិទ្យុនោះគុណនឹង ៥ ។

៦_២ ការផ្លាស់ប្តូររលកអាកាសវិទ្យុ ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណនឹង ៤ ។

៦_៣ ការផ្លាស់ប្តូរឋបនីយ៍ភ័ណ្ឌវិទ្យុ ឬ ទីតាំងឋបនភ័ណ្ឌវិទ្យុ ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណនឹង ៣ ។

៦_៤ ការប្រើប្រាស់អាជ្ញាប័ណ្ណហួសពេលកំណត់ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណនឹង ២ ។